**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ៖ បព ០៨/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចពិគ្រោះយោបល់ក្រៅផ្លូវការក្នុងទម្រង់ពង្រីក ស្តីពីការអនុវត្តកិច្ចព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុច

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៦ តបតាមការអញ្ជើញរបស់ **លោកជំទាវ ម៉ា តេរ៉េសា ភី ឡាហ្សារ៉ូ** រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋហ្វីលីពីន **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមកិច្ចពិគ្រោះយោបល់ក្រៅផ្លូវការក្នុងទម្រង់ពង្រីកស្តីពីការអនុវត្តកិច្ចព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុច (5PC) ដែលបានប្រព្រឹត្តទៅនៅកោះសេប៊ូ ប្រទេសហ្វីលីពីន។

កិច្ចប្រជុំបានស្វាគមន៍ការតែងតាំង **លោកជំទាវ ម៉ា តេរ៉េសា ភី ឡាហ្សារ៉ូ** ជាប្រេសិតពិសេសរបស់ប្រធានអាស៊ានស្តីពីមីយ៉ាន់ម៉ាសម្រាប់ឆ្នាំ២០២៦ និងបានបញ្ជាក់ជាថ្មីនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះអាណត្តិរបស់លោកជំទាវ ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងរបស់ហ្វីលីពីនក្នុងការជំរុញការអនុវត្ត 5PC ស្របតាមការវាយតម្លៃ និងសេចក្តីសម្រេចចិត្តរបស់ប្រមុខដឹកនាំអាស៊ានស្តីពីការអនុវត្ត 5PC ក្នុង ឆ្នាំ២០២៥។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានគូសបញ្ជាក់ថា 5PC នៅតែជាឯកសារគោលរបស់អាស៊ានក្នុងការជួយមីយ៉ាន់ម៉ាវិលទៅរកប្រក្រតីភាពឡើងវិញ តាមរយៈដំណើរការនយោបាយដែលដឹកនាំ និងគ្រប់គ្រងដោយមីយ៉ាន់ម៉ាខ្លួនឯង។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់លើការធានាថា 5PC នៅតែមានសារៈសំខាន់ និងប្រសិទ្ធភាព ដោយបានរំលេចអំពីការចាំបាច់ក្នុងការពិនិត្យឡើងវិញឱ្យបានទាន់ពេលវេលា ដើម្បីកំណត់មធ្យោបាយសមស្របឆ្ពោះទៅមុខ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបន្តលើកឡើងថា ដំណើរការបោះឆ្នោតដែលមានភាពអាចជឿជាក់បាន និងប្រកបដោយបរិយាបន្ន ទន្ទឹមនឹងការគាំទ្រពីប្រជាពលរដ្ឋមីយ៉ាន់ម៉ា គឺជាមធ្យោបាយដ៏សំខាន់មួយឆ្ពោះទៅកាន់ស្ថិរភាពយូរអង្វែង។

ក្នុងឱកាស នៃការចូលរួមកិច្ចពិគ្រោះយោបល់ក្រៅផ្លូវការក្នុងទម្រង់ពង្រីក **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជួបទ្វេភាគីជាមួយរដ្ឋមន្ត្រីការបរទេសនៃបណ្តាប្រទេសសមាជិកអាស៊ាន ដើម្បីពិភាក្សាអំពីបញ្ហាដែលជាផលប្រយោជន៍ និងក្តីកង្វល់រួម។

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ជាមួយ **ឯកឧត្តម ដាតូ អ៊ីរីវ៉ាន់ ពើហ៊ីន យូស៊ូហ៍** រដ្ឋមន្ត្រីការបរទេសទី២ នៃព្រុយណេដារ៉ូស្សាឡាម រដ្ឋមន្ត្រីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងមិត្តភាពដ៏ជិតស្និទ្ធរវាងប្រទេសទាំងពីរក្នុង ពេលបីទសវត្សរ៍កន្លងមកនេះ ដែលត្រូវបានពង្រឹងជាបន្តបន្ទាប់នៅលើវិស័យជាច្រើន ដើម្បីផលប្រយោជន៍ទៅវិញទៅមករបស់ប្រជាជន និងប្រជាជាតិទាំងពីរ។ ឯកឧត្តមរដ្ឋមន្ត្រីព្រុយណេ បានពាំនាំព្រះរាជសារថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅរបស់ **ព្រះចៅស៊ុលតង់** ជូន **សម្តេចតេជោ** ដែលបានផ្ញើលិខិតថ្វាយព្រះពរ ព្រះអង្គឆាប់ជាសះស្បើយក្រោយការវះកាត់ជង្គង់។

ជាមួយ **ឯកឧត្តម ទ្បេ ហ៉ាយជុង** រដ្ឋមន្ត្រីការបរទេសវៀតណាម រដ្ឋមន្ត្រីទាំងពីរបានផ្តោតសារៈសំខាន់យ៉ាងខ្លាំងទៅលើចំណងមិត្តភាពយូរអង្វែងរវាងកម្ពុជា-វៀតណាម ដោយផ្អែកលើមូលដ្ឋាន "ភាពជាអ្នកជិតខាងល្អ មិត្តភាពប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ និងស្ថិរភាពយូរអង្វែង"។ រដ្ឋមន្ត្រីទាំងពីរក៏បានរំលឹកអំពីលទ្ធផលប្រកបដោយផ្លែផ្កា នៃកិច្ចប្រជុំលើកទី២១ នៃគណៈកម្មការចម្រុះកម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលបានប្រព្រឹត្តទៅនៅខេត្តសៀមរាប នៅថ្ងៃទី៨-៩ ខែធ្នូ ឆ្នាំ២០២៥ ហើយក៏ពិភាក្សាអំពីការត្រៀមរៀបចំទស្សនកិច្ចផ្លូវរដ្ឋរបស់ **ឯកឧត្តម តូ ឡឹម** អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម នៅកម្ពុជា នាដើមខែកុម្ភៈ ឆ្នាំ២០២៦ ខាងមុខ។

ក្នុងជំនួបជាមួយ**ឯកឧត្តម ដាតុ ស៊េរី យូតាមា ហាជី មហាម៉ាដ ប៊ីន ហាជី ហាហ្សាន** រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវអំណរគុណសាជាថ្មីចំពោះម៉ាឡេស៊ី ដែលបានដើរតួនាទីយ៉ាងសកម្មក្នុងការសម្របសម្រួលឱ្យសម្រេចបានបទឈប់បាញ់ និងការឈានដល់កិច្ចព្រមព្រៀងសន្តិភាពរវាងកម្ពុជានិងថៃ។ រដ្ឋមន្ត្រីទាំងពីរ បានបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាបន្តធ្វើឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតនូវទំនាក់ទំនងទ្វេភាគីដ៏យូរអង្វែង និងបន្តជំរុញកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមកលើគ្រប់វិស័យ។ រដ្ឋមន្ត្រីទាំងពីរបានសម្តែងនូវក្តីទន្ទឹងរង់ចាំធ្វើជាសហប្រធានជាមួយគ្នាក្នុងកិច្ចប្រជុំគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការកម្ពុជា-ម៉ាឡេស៊ី លើកទី៣ ក្នុងឆ្នាំនេះ។

ក្នុងកិច្ចប្រជុំទ្វេភាគីខាងលើ បណ្តារដ្ឋមន្ត្រីក៏បានពិភាក្សាអំពីបញ្ហាតំបន់ និងអន្តរជាតិ ដែលជាផលប្រយោជន៍ និងកង្វល់រួម។ ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានធ្វើបច្ចុប្បន្នភាពជូនភាគីមិត្តអំពីស្ថានភាពតាមព្រំដែនកម្ពុជា-ថៃ៕

ថ្ងៃព្រហស្បតិ៍ ១១កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២៦